# ព្រះរាជក្រម

នស/រកម/១១០៥/០៣៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃ អនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់ចោលនូវ ការផ្ដល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់ចោលនូវការផ្ដល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងសម័យប្រជុំលើកទី ៤ តាមសេចក្ដីសម្រេចលេខ ៥៤/១០៩ ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ នៅទីក្រុងញូវយ៉ក ហើយដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាចូលជាភាគី នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

[illegible]

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា ព្រះហស្តលេខា**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

លេខៈ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

**[illegible] ចាន់**

# អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ចោល នូវការផ្តល់ហិរញ្ញប្បទាន ដល់អំពើភេរវកម្ម

អង្គការសហប្រជាជាតិ

១៩៩៩

# អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម

## បុព្វកថា

រដ្ឋសមាជិកទាំងអស់នៃអនុសញ្ញានេះ

*ដោយចងចាំនៅក្នុងចិត្ត* នូវគោលបំណង និង គោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ ទាក់ទងទៅនឹងការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ព្រមទាំងការលើកកំពស់ទំនាក់ទំនងជិតខាងល្អ ក៏ដូចជាចំណងមិត្តភាព និងសហប្រតិបត្តិការរវាងរដ្ឋទាំងឡាយ

*ដោយមានក្តីបារម្ភយ៉ាងជ្រៀលជ្រៅ* អំពីការរីករាលដាលនៅទូទាំងពិភពលោក នូវអំពើភេរវកម្ម តាមគ្រប់ទម្រង់ និងរូបភាព

*ដោយរំឭកទៅដល់* សេចក្តីប្រកាសនាឱកាសខួបលើកទីហាសិបនៃអង្គការសហប្រជាជាតិ ដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៥០/៦ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៥

*ដោយរំឭកផងដែរ* ទៅដល់សេចក្តីសម្រេចរបស់មហាសន្និបាត ដែលពាក់ព័ន្ធទៅនឹងបញ្ហានេះ រួមមានសេចក្តីសម្រេចលេខ ៤៩/៦០ ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ១៩៩៤ ព្រមទាំងឧបសម្ព័ន្ធរបស់វា ស្តីអំពីការប្រកាសវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មអន្តរជាតិ ដែលនៅក្នុងនោះ រដ្ឋសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ បានអះអាងជាថ្មីឡើងវិញ នូវការដាក់ទណ្ឌកម្មយ៉ាងច្បាស់លាស់ ទៅលើរាល់ទង្វើ វិធីសាស្ត្រ និង ការប្រតិបត្តិនូវអំពើភេរវកម្ម ថាជាអំពើឧក្រិដ្ឋកម្ម និងមិនអាចអត់ឱនឱ្យបាន ទោះជាអំពើនោះត្រូវបានប្រព្រឹត្តនៅទីណា ដោយនរណាក៏ដោយ ហើយរួមបញ្ចូលទាំងអំពើទាំងពួងដែលធ្វើឱ្យអន្តរាយទៅដល់ចំណងមិត្តភាពរវាងរដ្ឋទាំងឡាយ និងប្រជាជនទាំងឡាយ និងដែលគំរាមកំហែងទៅដល់បូរណភាពទឹកដី ព្រមទាំងសន្តិសុខរបស់រដ្ឋនានា

*ដោយកត់សំគាល់ឃើញថា* សេចក្តីប្រកាសស្តីអំពីវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មអន្តរជាតិ ក៏បានលើកទឹកចិត្តផងដែរ ឱ្យរដ្ឋទាំងឡាយធ្វើការពិនិត្យឡើងវិញជាបន្ទាន់ នូវវិសាលភាពនៃបទបញ្ញត្តិច្បាប់អន្តរជាតិដែលមានស្រាប់ ស្តីអំពីការបង្ការ ការបង្ក្រាប និងការលុបបំបាត់ចោល នូវអំពីភេរវកម្មគ្រប់ទម្រង់ និងគ្រប់រូបភាព ក្នុងគោលបំណងធ្វើការធានាឱ្យបានថា មានក្របខ័ណ្ឌច្បាប់យ៉ាងទូលំទូលាយ សម្រាប់គ្រប់គ្រងទៅលើរាល់ទិដ្ឋភាពនៃបញ្ហានេះ

*ដោយរំឭកទៅដល់* កថាខ័ណ្ឌទី៣ វាក្យខ័ណ្ឌ(ច) នៃសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៥១/២១០ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលនៅក្នុងនោះ មហាសន្និបាតបានអំពាវនាវដល់រដ្ឋទាំងអស់ ឱ្យធ្វើការបង្ការ និងរារាំង តាមរយៈវិធានការក្នុងស្រុកសមស្រប ចំពោះការផ្តល់ហិរញ្ញប្បទានទៅដល់ភេរវករ និងអង្គការភេរវកម្មនានា ទោះបីជាការផ្តល់ហិរញ្ញប្បទាននោះ ធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោលតាមរយៈអង្គការនានា ដែលមាន ឬអះអាងថាមានគោលដៅ

សប្បុរសធម៌ សង្គម ឬវប្បធម៌ ឬដែលធ្វើសកម្មភាពខុសច្បាប់ ដូចជាការជួញដូរអាវុធខុសច្បាប់ ការរកស៊ីខាងគ្រឿងញៀន និងបទទុច្ចរិតផ្សេងទៀត រួមមានការធ្វើអាជីវកម្មលើមនុស្សក្នុងគោលបំណងផ្ដល់ហិរញ្ញប្បទានដល់សកម្មភាពភេរវកម្ម និងជាពិសេសឱ្យធ្វើការពិចារណា ក្នុងករណីដែលសមស្រប អំពីការបង្កើតវិធានការនិយ័តកម្ម ដើម្បីបង្ការ និងរាំងការធ្វើចរាចរណ៍នៃមូលនិធិដែលត្រូវបានសង្ស័យថាមានគោលដៅបំរើឱ្យសកម្មភាពភេរវកម្ម ដោយធ្វើយ៉ាងណាមិនឱ្យប៉ះពាល់ ទៅដល់សេរីភាពនៃការធ្វើចរាចរណ៍មូលធនស្របច្បាប់ និងឱ្យពង្រីងការផ្លាស់ប្ដូរព័ត៌មានដែលទាក់ទងទៅនឹងចរាចរណ៍ជាអន្តរជាតិ នៃមូលនិធិបែបនេះ

*ដោយរំឭកផងដែរ* ទៅដល់សេចក្ដីសម្រេចរបស់មហាសន្និបាត លេខ ៥២/១៦៥ ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧ ដែលនៅក្នុងនោះ មហាសន្និបាតបានអំពាវនាវដល់រដ្ឋទាំងអស់ ឱ្យធ្វើការពិចារណាជាពិសេសទៅលើការអនុវត្តវិធានការនានា ដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី៣ (ក) ដល់ (ច) នៃសេចក្ដីសម្រេចរបស់មហាសន្និបាត លេខ ៥២/២១០ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៦

*ដោយរំឭកបន្តទៀត* ទៅដល់សេចក្ដីសម្រេចរបស់មហាសន្និបាត លេខ ៥៣/១០៨ ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ១៩៩៨ ដែលនៅក្នុងនោះ មហាសន្និបាតបានសម្រេចថា គណៈកម្មាធិការអាដហុក ដែលត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់មហាសន្និបាត លេខ ៥១/២១០ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៦ គួរតែធ្វើការតាក់តែងសេចក្ដីព្រាងនៃអនុសញ្ញាអន្តរជាតិមួយ ស្ដីអំពីការលុបបំបាត់ចោល នូវការផ្ដល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ដើម្បីបំពេញបន្ថែមទៅលើលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធដែលមានស្រាប់

*ដោយយល់ឃើញថា* ការផ្ដល់ហិរញ្ញប្បទានទៅដល់អំពើភេរវកម្ម គឺជាបញ្ហាមួយដែលបង្កក្ដីបារម្ភយ៉ាងធ្ងន់ធ្ងរចំពោះសហគមន៍អន្តរជាតិទាំងមូល

*ដោយកត់សំគាល់ឃើញថា* ចំនួន និងភាពធ្ងន់ធ្ងរនៃអំពើភេរវកម្មអន្តរជាតិ អាស្រ័យទៅលើហិរញ្ញប្បទានដែលភេរវករអាចនឹងទទួលបាន

*ដោយកត់សំគាល់ឃើញផងដែរថា* លិខិតូបករណ៍គតិយុត្តិពហុភាគីដែលមានស្រាប់ ពុំបានកំណត់ឱ្យបានច្បាស់លាស់អំពីការផ្ដល់ហិរញ្ញប្បទានបែបនេះ

*ដោយយល់* អំពីតម្រូវការបន្ទាន់ដើម្បីលើកកំពស់សហប្រតិបត្តិអន្តរជាតិ រវាងរដ្ឋទាំងឡាយ ក្នុងការបង្កើត និងអនុម័តវិធានការប្រកបដោយប្រសិទ្ធិភាព សម្រាប់ការបង្ការការផ្ដល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម ក៏ដូចជាសម្រាប់ការលុបបំបាត់ទង្វើទាំងនោះ តាមរយៈការចោទប្រកាន់ និងការដាក់ទណ្ឌកម្មទៅលើអ្នកប្រព្រឹត្ត

**បានព្រមព្រៀងគ្នាដូចតទៅនេះ**

**មាត្រា ១**

សម្រាប់គោលបំណងនៃអនុសញ្ញានេះ :

១. " មូលនិធិ " មានន័យថាជាទ្រព្យសម្បត្តិគ្រប់ប្រភេទ ទោះរូបី ឬអរូបីក្តី ជាចលនវត្ថុ ឬអចលនវត្ថុក្តី ត្រូវបានធ្វើលទ្ធកម្មតាមរបៀបណាក្តី, ព្រមទាំងឯកសារ ឬលិខិតូបករណ៍គតិយុត្តិគ្រប់រូបភាព រួមទាំងឧបករណ៍អេឡិចត្រូនិច ឬឌីជីថល វត្ថុសំគាល់កម្មសិទ្ធិ ឬផលប្រយោជន៍ដែលបានពីទ្រព្យទាំងនោះ រួមមាន ឥណទានធនាគារ មូលប្បទានប័ត្រអ្នកដំណើរ មូលប្បទានប័ត្រធនាគារ អាណត្តិបើកប្រាក់ ភាគហ៊ុន ប័ណ្ណភាគហ៊ុន ប័ណ្ណកំចី រូបិយាណត្តិ លិខិតឥណទាន ជាដើម ។

២. " អង្គភាពរបស់រដ្ឋ ឬរដ្ឋាភិបាល " មានន័យថាជាអង្គភាព ឬស្ថាប័នដឹកនាំជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នណាដែល ត្រូវបានប្រើប្រាស់ ឬកាន់កាប់ដោយអ្នកតំណាងរបស់រដ្ឋ សមាជិកនៃរដ្ឋាភិបាល អង្គការនីតិបញ្ញត្តិ ឬអង្គការតុលាការ ឬ ដោយមន្ត្រី ឬនិយោជិតរបស់រដ្ឋ ឬអាជ្ញាធរ ឬអង្គការសាធារណៈដទៃទៀត ឬ ដោយនិយោជិត ឬមន្ត្រីនៃអង្គការអន្តររដ្ឋាភិបាលណាមួយ នៅក្នុងទំនាក់ទំនងទៅនឹងភារកិច្ចជាផ្លូវការរបស់ពួកគេ ។

៣. " ប្រាក់ចំណូល " មានន័យថាជាមូលនិធិដែលកើតចេញ ឬដែលទទួលបាន ដោយផ្ទាល់ ឬដោយប្រយោល ពីការប្រព្រឹត្តបទល្មើសណាមួយដែលមានចែងនៅក្នុងមាត្រា ២ ។

**មាត្រា ២**

១. ជនណាក៏ដោយ ត្រូវចាត់ទុកថាប្រព្រឹត្តបទល្មើសនៅក្នុងអត្ថន័យនៃអនុសញ្ញានេះ ប្រសិនបើជននោះ ផ្តល់ ឬ ប្រមូល តាមវិធីណាក៏ដោយ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ដោយផ្ទុយនឹងច្បាប់ និងដោយចេតនា នូវមូលនិធិ ដោយចេតនាថាមូលនិធិទាំងនោះគួរតែត្រូវយកប្រើប្រាស់ ឬដោយដឹងថាមូលនិធិទាំងនោះត្រូវយកទៅប្រើប្រាស់ ទាំងអស់ ឬ មួយភាគ ដើម្បីប្រព្រឹត្ត :

(ក) អំពើណាមួយដែលបង្កជាបទល្មើស នៅក្នុងទំហំ និងដែលត្រូវបានកំណត់នៅក្នុងសន្ធិសញ្ញាណាមួយ ក្នុងចំណោមសន្ធិសញ្ញាដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ឬ

(ខ) អំពើដទៃទៀតណាមួយ ដែលមានគោលបំណងបង្កឱ្យមានការស្លាប់ ឬរបួសរាងកាយធ្ងន់ធ្ងរ ដល់ជនស៊ីវិលណាម្នាក់ ឬ ដល់បុគ្គលផ្សេងទៀត ដែលពុំមែនជាសកម្មជននៃអរិភាពនៅក្នុងស្ថានភាពនៃជំលោះប្រដាប់អាវុធ នៅពេលណាដែលគោលបំណងនៃអំពើបែបនេះ តាមរយៈលក្ខណៈ ឬ បរិបទរបស់វា គឺដើម្បីធ្វើការបំភិតបំភ័យដល់ប្រជាជន ឬដើម្បីបង្ខិតបង្ខំរដ្ឋាភិបាលណាមួយ ឬអង្គការអន្តរជាតិណាមួយ ឱ្យធ្វើ ឬមិនធ្វើអំពើណាមួយ ។

២. (ក) នៅពេលដាក់លិខិតូបករណ៍សម្រាប់ការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការយល់ព្រម ឬការចូលជាសមាជិក រដ្ឋភាគីណាដែលពុំមែនជាភាគីនៃសន្ធិសញ្ញាណាមួយដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ អាចធ្វើការប្រកាសថា នៅក្នុងការអនុវត្តអនុសញ្ញានេះចំពោះរដ្ឋភាគី សន្ធិសញ្ញានោះត្រូវចាត់ទុកថាមិនស្ថិតនៅក្នុងឧបសម្ព័ន្ធដែលបានចែងនៅក្នុងកថាខ័ណ្ឌទី ១ វាក្យខ័ណ្ឌ (ក) ទេ ។ សេចក្តីប្រកាសនេះ ត្រូវអស់សុពលភាព នៅពេលណាដែលសន្ធិសញ្ញានោះ ចូលជាធរមាន ចំពោះរដ្ឋភាគីនោះ ហើយរដ្ឋភាគីនោះ ត្រូវជូនដំណឹងដល់កន្លែងតម្កល់ អំពីការណ៍នេះ ។

(ខ) នៅពេលណាដែលរដ្ឋភាគីណាមួយ លែងជាភាគីនៃសន្ធិសញ្ញាណាមួយដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទៀតហើយ រដ្ឋនោះអាចធ្វើសេចក្តីប្រកាសដូចដែលមានចែងនៅក្នុងមាត្រានេះ ចំពោះសន្ធិសញ្ញានោះ ។

៣. អំពើមួយអាចត្រូវបានចាត់ទុកថាបង្កជាបទល្មើសមួយដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ ដោយពុំចាំបាច់បង្ហាញថា មូលនិធិត្រូវបានប្រើប្រាស់យ៉ាងជាក់ស្តែង ដើម្បីប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ វាក្យខ័ណ្ឌ (ក) ឬ (ខ) ឡើយ ។

៤. ជនណាក៏ដោយ ក៏ត្រូវចាត់ទុកថាប្រព្រឹត្តបទល្មើសដែរ ប្រសិនបើជននោះ ប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ ។

៥. ជនណាក៏ដោយ ក៏ត្រូវចាត់ទុកថាប្រព្រឹត្តបទល្មើសដែរ ប្រសិនបើជននោះ :

(ក) ចូលរួមក្នុងនាមជាអ្នកសមគំនិត នៅក្នុងបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ ឬទី៤ នៃមាត្រានេះ

(ខ) រៀបចំ ឬដឹកនាំអ្នកដទៃ ឱ្យប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ ឬទី៤ នៃមាត្រានេះ

(គ) ចូលរួមចំណែកទៅក្នុងការប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ ឬទី៤ នៃមាត្រានេះ ដោយក្រុមបុគ្គលដែលធ្វើសកម្មភាពក្នុងគោលបំណងរួមគ្នា ។ ការចូលរួមចំណែកនេះ ត្រូវជាការចូលរួមចំណែកដោយចេតនា ហើយត្រូវធ្វើឡើងដោយ :

(១) មានគោលបំណងជួយជ្រោមជ្រែងដល់សកម្មភាពឧក្រិដ្ឋ ឬគោលបំណងឧក្រិដ្ឋ របស់ក្រុម ក្នុងករណីដែលសកម្មភាព ឬគោលបំណងនោះ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌ ទី១ នៃមាត្រានេះ ឬមួយ

(២) ដឹងអំពីចេតនារបស់ក្រុម ក្នុងការប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ។

**មាត្រា ៣**

អនុសញ្ញានេះ មិនត្រូវយកទៅអនុវត្តឡើយ នៅក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងរដ្ឋតែមួយ, ជនល្មើសជាប់ចោទជាពលរដ្ឋរបស់រដ្ឋនោះ និងមានវត្តមាននៅលើទឹកដីរបស់រដ្ឋនោះ ហើយពុំមានរដ្ឋណាមួយផ្សេងទៀតអាចលើកមូលដ្ឋាននៃកថាខ័ណ្ឌទី១ នៃមាត្រា៧ ឬ កថាខ័ណ្ឌទី២ នៃមាត្រា៧ ដើម្បីអនុវត្តយុត្តាធិការរបស់ខ្លួនលើបទល្មើសនោះ, លើកលែងតែថា បទបញ្ញត្តិនៃមាត្រា ១២ ដល់មាត្រា ១៨ ត្រូវយកទៅអនុវត្តចំពោះករណីទាំងនោះ នៅពេលណាសមស្រប ។

## មាត្រា ៤

រដ្ឋភាគីនីមួយៗ ត្រូវបង្កើតវិធានការដូចខាងក្រោមនេះ ទៅតាមការចាំបាច់ :

(ក) ត្រូវកំណត់នៅក្នុងច្បាប់ជាតិរបស់ខ្លួន ថាបទល្មើសដែលមានចែងនៅក្នុងមាត្រា២ គឺជាបទល្មើស ព្រហ្មទណ្ឌ

(ខ) ត្រូវដាក់ទោសទៅលើបទល្មើសទាំងនោះ ដោយប្រើទណ្ឌកម្មសមស្រប ដោយគិតពិចារណាទៅលើលក្ខណៈធ្ងន់ធ្ងរនៃបទល្មើស ។

## មាត្រា ៥

១. រដ្ឋភាគីនីមួយៗ ដោយអនុលោមទៅតាមគោលការណ៍ច្បាប់ជាតិរបស់ខ្លួន ត្រូវចាត់វិធានការចាំបាច់ដើម្បីធ្វើឱ្យនីតិបុគ្គលណាមួយដែលមានទីតាំងនៅក្នុងទឹកដីរបស់ខ្លួន ឬដែលត្រូវបានគ្រប់គ្រងដោយច្បាប់របស់ខ្លួន មានការទទួលខុសត្រូវនៅពេលណាដែលជនណាម្នាក់ដែលមានភារៈទទួលខុសត្រូវលើការគ្រប់គ្រង ឬត្រួតពិនិត្យនីតិបុគ្គលនោះ បានប្រព្រឹត្តបទល្មើសដែលចែងនៅក្នុងមាត្រា២ ដោយប្រើសមត្ថភាពក្នុងតួនាទីរបស់ខ្លួននោះ ។ ការទទួលខុសត្រូវនេះ អាចជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬរដ្ឋបាល ។

២. ការទទួលខុសត្រូវនេះ ត្រូវធ្វើឡើងដោយមិនប៉ះពាល់ទៅដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ របស់រូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើសឡើយ ។

៣. រដ្ឋភាគីនីមួយៗ ត្រូវធ្វើការធានាជាពិសេសឱ្យបានថា នីតិបុគ្គលដែលត្រូវទទួលខុសត្រូវតាមបញ្ញត្តិនៃកថាខ័ណ្ឌទី១ខាងលើនេះ ទទួលរងនូវទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬរដ្ឋបាល ដែលមានប្រសិទ្ធិភាព មានលក្ខណៈសមស្រប និងអាចធ្វើឱ្យមានភាពរាងចាល ។ ទណ្ឌកម្មទាំងនេះ អាចរួមបញ្ចូលផងដែរ នូវទណ្ឌកម្មជាប្រាក់ ។

ទៅតាមការចាំបាច់ រដ្ឋភាគីនីមួយៗត្រូវបង្កើតវិធានការទាំងឡាយ ដែលនៅពេលណាសមស្រប រួមបញ្ចូលនូវការបង្កើតច្បាប់ជាតិ ដើម្បីធានាឱ្យបានថា សកម្មភាពព្រហ្មទណ្ឌដែលស្ថិតនៅក្នុងវិសាលភាពនៃអនុសញ្ញានេះ នឹងមិនត្រូវបានអត់ឱនឱ្យ ដោយគិតពីចារណាទៅលើលក្ខណៈនយោបាយ ទស្សនវិជ្ជា មនោគមនវិជ្ជា ពូជសាសន៍ ជាតិពន្ធ សាសនា ឬលក្ខណៈប្រហាក់ប្រហែលផ្សេងទៀតឡើយ ទោះក្នុងកាលៈទេសៈបែបណាក៏ដោយ ។

**មាត្រា ៧**

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការ ទៅតាមការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន ទៅលើបទល្មើសដែលមានចែងនៅក្នុងមាត្រា២ នៅពេលណាដែល :

(ក) បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីនៃរដ្ឋនោះ

(ខ) បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងនាវាដែលដោតទង់ជាតិនៃរដ្ឋនោះ ឬនៅក្នុងអាកាសយានដែលចុះបញ្ជីតាមច្បាប់នៃរដ្ឋនោះ នៅពេលប្រព្រឹត្តបទល្មើស

(គ) បទល្មើសត្រូវបានប្រព្រឹត្តដោយពលរដ្ឋនៃរដ្ឋនោះ ។

២. រដ្ឋភាគីក៏អាចបង្កើតយុត្តាធិការរបស់ខ្លួន ទៅលើបទល្មើសទាំងនោះផងដែរ នៅពេលណាដែល :

(ក) បទល្មើសត្រូវបានតម្រង់ទិសទៅរក ឬ ជាលទ្ធផលនៃ ការប្រព្រឹត្តបទល្មើសណាមួយដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ វាក្យខ័ណ្ឌ (ក) ឬ (ខ) នៃមាត្រា២ នៅក្នុងទឹកដីនៃរដ្ឋនោះ ឬ ប្រឆាំងទៅនឹងពលរដ្ឋណាម្នាក់នៃរដ្ឋនោះ

(ខ) បទល្មើសត្រូវបានតម្រង់ទិសទៅរក ឬ ជាលទ្ធផលនៃ ការប្រព្រឹត្តបទល្មើសណាមួយដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ វាក្យខ័ណ្ឌ (ក) ឬ (ខ) នៃមាត្រា២ ប្រឆាំងទៅនឹងអង្គភាពរបស់រដ្ឋ ឬរដ្ឋាភិបាល នៃរដ្ឋនោះ នៅឯបរទេសដែលរួមមានបរិវេណការទូត ឬកុងស៊ុល របស់រដ្ឋនោះ

(គ) បទល្មើសត្រូវបានតម្រង់ទិសទៅរក ឬ ជាលទ្ធផលនៃ បទល្មើសណាមួយដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ វាក្យខ័ណ្ឌ (ក) ឬ (ខ) នៃមាត្រា២ ដែលត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងធ្វើការបង្ខិតបង្ខំឱ្យរដ្ឋនោះ ធ្វើ ឬមិនធ្វើសកម្មភាពណាមួយ

(ឃ) បទល្មើសត្រូវបានប្រព្រឹត្តឡើងដោយជនគ្មានសញ្ជាតិណាម្នាក់ ដែលមានទីលំនៅ/និវេសនដ្ឋានប្រចាំរបស់ខ្លួន នៅលើទឹកដីនៃរដ្ឋនោះ

(ង) បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងអាកាសយានណាមួយ ដែលធ្វើអាជីវកម្មដោយរដ្ឋាភិបាលនៃរដ្ឋនោះ ។

៣. នៅពេលផ្តល់សច្ចាប័ន ទទួលស្គាល់ ទទួលយល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋភាគីនីមួយៗត្រូវជូនដំណឹងដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ អំពីយុត្តាធិការដែលខ្លួនបានបង្កើតតាមកថាខ័ណ្ឌទី២ ខាងលើ ។ ប្រសិនបើមានការផ្លាស់ប្តូរណាមួយកើតឡើង រដ្ឋភាគីដែលមានការពាក់ព័ន្ធ ត្រូវជូនដំណឹងជាបន្ទាន់ ទៅដល់អគ្គលេខាធិការ ។

៤. ក៏ដូចគ្នាផងដែរ រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការតាមការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន ទៅលើបទល្មើសទាំងឡាយដែលមានចែងនៅក្នុងមាត្រា២ នៅក្នុងករណីដែលជនល្មើសជាប់ចោទ មានវត្តមាននៅលើទឹកដីរបស់ខ្លួន ហើយខ្លួនមិនធ្វើបត្យាប័នជននោះ ទៅឱ្យរដ្ឋភាគីណាមួយ ដែលបានបង្កើតយុត្តាធិការតាមបញ្ញត្តិនៃកថាខ័ណ្ឌទី១ ឬ ទី២ ខាងលើ ។

៥. នៅពេលណាដែលមានរដ្ឋចាប់ពីពីរឡើងទៅ ទាមទារយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសដែលមានចែងនៅក្នុងមាត្រា២ រដ្ឋដែលពាក់ព័ន្ធត្រូវខិតខំធ្វើយ៉ាងណាសម្របសម្រួលសកម្មភាពរបស់ខ្លួនឱ្យសមស្រប ជាពិសេសទាក់ទងទៅនឹងល័ក្ខខ័ណ្ឌនៃការចោទប្រកាន់ ព្រមទាំងបែបបទនានា សម្រាប់ការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ។

៦. ដោយមិនធ្វើឱ្យប៉ះពាល់ទៅដល់បទដ្ឋាននៃច្បាប់អន្តរជាតិទូទៅ អនុសញ្ញានេះមិនបដិសេធចោលនូវការអនុវត្តយុត្តាធិការព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងដោយរដ្ឋភាគីណាមួយ ទៅតាមច្បាប់ជាតិរបស់រដ្ឋនោះឡើយ ។

## មាត្រា ៨

១. រដ្ឋភាគីនីមួយៗត្រូវត្រូវចាត់វិធានការសមរម្យ ទៅតាមគោលការណ៍ច្បាប់ជាតិរបស់ខ្លួន ក្នុងការកំណត់មុខ សញ្ញាស៊ើបរក និងបញ្ឈប់ ឬរឹបអូសមូលនិធិទាំងឡាយណាដែលត្រូវបានប្រើប្រាស់ ឬផ្តល់ឱ្យ សម្រាប់គោលបំណងនៃការប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ក៏ដូចជាប្រាក់ចំណូលដែលបានមកពីបទល្មើសទាំងនោះ ក្នុងគោលបំណងធ្វើការរឹបអូស ។

២. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការសមស្រប ទៅតាមគោលការណ៍ច្បាប់ជាតិរបស់ខ្លួន ក្នុងការរឹបអូសយកនូវមូលនិធិដែលត្រូវបានប្រើប្រាស់ ឬផ្តល់ឱ្យ សម្រាប់គោលបំណងនៃការប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ព្រមទាំងប្រាក់ចំណូលដែលបានមកពីបទល្មើសទាំងនោះផង ។

៣. រដ្ឋភាគីនីមួយៗដែលមានការពាក់ព័ន្ធ អាចធ្វើការពិចារណាអំពីការចុះកិច្ចព្រមព្រៀងជាទៀងទាត់ ឬតាមករណីនីមួយៗ ស្តីអំពីការបែងចែកជាមួយរដ្ឋភាគីដទៃទៀត នូវមូលនិធិដែលរឹបអូសបានតាមបញ្ញត្តិនៃមាត្រានេះ ។

៤. រដ្ឋភាគីនីមួយៗ ត្រូវគិតគូរអំពីការបង្កើតយន្តការនានា ដែលតាមរយៈនោះ មូលនិធិដែលរឹបអូសបានតាមបញ្ញត្តិនៃមាត្រានេះ នឹងត្រូវបានយកទៅប្រើប្រាស់ដើម្បីសងជាសំណងដល់ជនរងគ្រោះដោយសារបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ វាក្យខ័ណ្ឌ (ក) ឬ (ខ) នៃមាត្រា២ ឬដល់ក្រុមគ្រួសាររបស់ពួកគេ ។

៥. បទបញ្ញត្តិនៃមាត្រានេះ ត្រូវយកទៅអនុវត្ត ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ដែលធ្វើសកម្មភាពដោយសុចរិតឡើយ ។

## មាត្រា ៩

១. នៅពេលណាដែលបានទទួលពត៌មានថា ជនដែលបានប្រព្រឹត្ត ឬដែលជាប់ចោទថាបានប្រព្រឹត្តបទល្មើស ដែលមានចែងនៅក្នុងមាត្រា២ ប្រហែលជាមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន រដ្ឋភាគីដែលមានការពាក់ព័ន្ធ ត្រូវចាត់វិធានការ តាមការចាំបាច់ ទៅតាមច្បាប់ជាតិរបស់ខ្លួន ក្នុងការស៊ើបអង្កេតលើអង្គហេតុដែលមាននៅក្នុងពត៌មាននោះ ។

២. នៅពេលណាមានការទុកចិត្តថាកាលៈទេសៈហុចឱ្យហើយ រដ្ឋភាគីដែលជនល្មើស ឬជនដែលជាប់ចោទថាជាជនល្មើស មានវត្តមាននៅលើទឹកដីរបស់ខ្លួន ត្រូវចាត់វិធានការសមស្រប ទៅតាមច្បាប់ជាតិរបស់ខ្លួន ដើម្បីធានាឱ្យបាននូវវត្តមានរបស់ជននោះ ក្នុងគោលបំណងធ្វើការចោទប្រកាន់ ឬធ្វើបត្យាប័នជននោះ ។

៣. ជនទាំងឡាយណា ដែលវិធានការនៅក្នុងកថាខ័ណ្ឌទី២ កំពុងត្រូវបានចាត់ឡើងចំពោះខ្លួន ត្រូវមានសិទ្ធិ :

(ក) ធ្វើការទាក់ទងដោយគ្មានការយឺតយ៉ាវ ជាមួយនឹងអ្នកតំណាងសមស្របដែលនៅជិតបំផុត នៃរដ្ឋដែលជននោះជាពលរដ្ឋ ឬនៃរដ្ឋដែលទទួលសិទ្ធិការពារសិទ្ធិរបស់ជននោះ ឬ នៃរដ្ឋដែលជននោះស្នាក់នៅជាប្រចាំលើទឹកដីរបស់ខ្លួន ប្រសិនបើជននោះពុំមានសញ្ជាតិទេ

(ខ) ទទួលការសួរសុខទុក្ខពីសំណាក់អ្នកតំណាងរបស់រដ្ឋនោះ

(គ) ទទួលពត៌មានអំពីសិទ្ធិរបស់ខ្លួន តាមបញ្ញត្តិនៃវាក្យខ័ណ្ឌ (ក) និង (ខ) ។

៤. សិទ្ធិដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី៣ខាងលើ ត្រូវអនុវត្តឱ្យស្របទៅតាមច្បាប់ និងបទបញ្ញត្តិនានា នៃរដ្ឋដែលជនល្មើស ឬជនដែលជាប់ចោទថាជាជនល្មើស មានវត្តមាននៅលើទឹកដីរបស់ខ្លួន ។ ប៉ុន្តែ ច្បាប់ និងបទបញ្ញត្តិទាំងនោះត្រូវគោរពសិទ្ធិដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី៣ខាងលើ ។

៥. បញ្ញត្តិនៃកថាខ័ណ្ឌទី៣ និងទី៤ ខាងលើ មិនត្រូវរាំងរាដល់សិទ្ធិរបស់រដ្ឋណាមួយដែលបានធ្វើការទាមទារយុត្តាធិការតាមបញ្ញត្តិនៃកថាខ័ណ្ឌទី១ វាក្យខ័ណ្ឌ (ខ) ឬ កថាខ័ណ្ឌទី២ វាក្យខ័ណ្ឌ (ខ) នៃមាត្រា ៧ ក្នុងការអញ្ជើញគណៈកម្មការកាកបាទក្រហមអន្តរជាតិ ឱ្យធ្វើការទាក់ទង ឬសួរសុខទុក្ខជនល្មើសដែលជាប់ចោទ ឡើយ ។

៦. នៅពេលណាដែលរដ្ឋភាគីណាមួយ បានឃុំខ្លួនជនល្មើស តាមបញ្ញត្តិនៃមាត្រានេះ រដ្ឋនោះត្រូវជូនដំណឹងជាបន្ទាន់ដោយផ្ទាល់ ឬតាមរយៈអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ទៅដល់រដ្ឋភាគីទាំងឡាយដែលបានបង្កើតយុត្តាធិការតាមបញ្ញត្តិនៃកថាខ័ណ្ឌទី១ ឬទី២ នៃមាត្រា៧ និងទៅដល់រដ្ឋភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធផ្សេងទៀត ប្រសិនបើខ្លួនយល់ឃើញថាសមគួរ អំពីការណ៍ដែលជននោះស្ថិតក្នុងការឃុំឃាំង និងអំពីកាលៈទេសៈដែលនាំទៅដល់ការឃុំខ្លួនជននោះ ។ រដ្ឋដែលធ្វើការស៊ើបអង្កេតតាមបញ្ញត្តិនៃកថាខ័ណ្ឌទី១ ត្រូវជូនដំណឹងភ្លាម ទៅដល់រដ្ឋភាគីផ្សេងទៀតដែលបានពោលខាងលើអំពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ហើយត្រូវធ្វើការបញ្ជាក់ថាតើខ្លួនមានបំណងអនុវត្តយុត្តាធិការ ដែរឬទេ ។

**មាត្រា ១០**

១. ក្នុងករណីទាំងឡាយដែលត្រូវយកមាត្រា៧ មកអនុវត្ត ប្រសិនបើខ្លួនមិនធ្វើបត្យាប័នជនដែលជាប់ចោទថាជាជនល្មើសទេ រដ្ឋភាគីដែលជននោះមានវត្តមាននៅលើទឹកដីរបស់ខ្លួន ត្រូវមានកាតព្វកិច្ចបញ្ជូនសំណុំរឿងនោះ ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ទៅតាមនីតិវិធីនៃច្បាប់របស់រដ្ឋនោះ ឱ្យបានទាន់ពេល និងដោយពុំមានការលើកលែងថាបទល្មើសនោះត្រូវបានប្រព្រឹត្តយ៉ាងណា ឬថាបទល្មើសនោះត្រូវបាន ប្រព្រឹត្តនៅលើទឹកដីនៃរដ្ឋ នោះ ឬមិនមែននោះឡើយ ។ អាជ្ញាធរទាំងនោះ ត្រូវចេញសេចក្ដីសម្រេចរបស់ខ្លួន តាមវិធីដូចគ្នាទៅនឹងករណីនៃបទល្មើស ដទៃទៀតដែលមានលក្ខណៈធ្ងន់ធ្ងរ ទៅតាមច្បាប់របស់រដ្ឋនោះ ។

២. នៅពេលណាដែលរដ្ឋភាគីណាមួយត្រូវបានអនុញ្ញាតដោយច្បាប់ជាតិរបស់ខ្លួន ឱ្យធ្វើបត្យាប័ន ឬប្រគល់ពលរដ្ឋណាម្នាក់ក្នុងចំណោមពលរដ្ឋរបស់ខ្លួន ទៅឱ្យរដ្ឋដទៃ តាមល័ក្ខខ័ណ្ឌដែលថាជននោះនឹងត្រូវបានប្រគល់ត្រឡប់ឱ្យមកទទួលទោសតាមការកាត់សេចក្ដី ឬតាមនីតិវិធីដែលកំណត់ដោយរដ្ឋដែលទទួលបត្យាប័ន ឬទទួលការប្រគល់ នៅឯរដ្ឋដែលបានធ្វើបត្យាប័ន ឬដែលបានប្រគល់ ហើយប្រសិនបើរដ្ឋទាំងពីរនេះ ព្រមព្រៀងលើជំរើសបែបនេះ និងលើល័ក្ខខ័ណ្ឌដទៃទៀតដែលពួកគេអាចនឹងយល់ឃើញថាសមរម្យ បត្យាប័ន ឬការប្រគល់ដែលភ្ជាប់ជាមួយល័ក្ខខ័ណ្ឌនេះ ត្រូវជាការគ្រប់គ្រាន់ ដើម្បីរំលត់កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី១ ។

**មាត្រា ១១**

១. បទល្មើសដែលមានចែងនៅក្នុងមាត្រា២ ត្រូវចាត់ទុកថាបានបញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័នបាន នៅក្នុងសន្ធិសញ្ញាបត្យាប័នទាំងឡាយដែលមានស្រាប់ រវាងរដ្ឋភាគី នៅមុនពេលអនុសញ្ញានេះចូលជាធរមាន ។ រដ្ឋភាគីទាំងឡាយទទួលរ៉ាប់រងការបញ្ចូលបទល្មើសទាំងនេះ ជាបទល្មើសដែលអាចធ្វើបត្យាប័នបាន ទៅក្នុងរាល់សន្ធិសញ្ញាបត្យាប័ននានា ដែលត្រូវចុះជាបន្តបន្ទាប់ រវាងរដ្ឋភាគីទាំងនោះ ។

២. នៅពេលរដ្ឋភាគីណាមួយ ដែលធ្វើបត្យាប័នទៅតាមល័ក្ខខ័ណ្ឌអត្ថិភាពនៃសន្ធិសញ្ញា បានទទួលសំណើសុំបត្យាប័ន ពីរដ្ឋភាគីណាមួយទៀតដែលខ្លួនពុំបានចុះសន្ធិសញ្ញាបត្យាប័នជាមួយ. តាមជំរើសរបស់ខ្លួន រដ្ឋដែលបានទទួលសំណើនោះ អាចចាត់ទុកថាអនុសញ្ញានេះ គឺជាមូលដ្ឋានច្បាប់សម្រាប់ការធ្វើបត្យាប័ន ចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ។ ការធ្វើបត្យាប័ន ត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដទៃទៀត ដែលកំណត់ដោយច្បាប់នៃរដ្ឋដែលទទួលសំណើនោះ ។

៣. រដ្ឋភាគីទាំងឡាយដែលពុំធ្វើបត្យាប័នទៅតាមល័ក្ខខ័ណ្ឌអត្ថិភាពនៃសន្ធិសញ្ញាទេ ត្រូវទទួលស្គាល់បទល្មើសដែលមានចែងនៅក្នុងមាត្រា២ ថាជាបទល្មើសដែលអាចធ្វើបត្យាប័នបាន រវាងរដ្ឋទាំងនោះ ហើយត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់នៃរដ្ឋដែលទទួលសំណើសុំបត្យាប័ន ។

៤. ប្រសិនបើចាំបាច់ និងសម្រាប់គោលបំណងនៃការធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសទាំងឡាយដែលមានចែងនៅក្នុងមាត្រា២ ត្រូវទុកដូចជាបានប្រព្រឹត្តមិនត្រឹមតែនៅកន្លែងដែលវាកើតឡើងទេ តែនៅលើទឹកដីនៃរដ្ឋដែលបានបង្កើតយុត្តាធិការ តាមបញ្ញត្តិនៃកថាខ័ណ្ឌទី១ និងទី២ នៃមាត្រា៧ ផងដែរ ។

៥. បទបញ្ញត្តិនៃរាល់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងអស់ ស្តីអំពីការធ្វើបត្យាប័ន រវាងរដ្ឋភាគីទាំងឡាយ ចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ត្រូវចាត់ទុកថាបានកែប្រែរវាងរដ្ឋភាគីទាំងនោះ ត្រឹមទំហំដែលផ្ទុយទៅនឹងអនុសញ្ញានេះ ។

**មាត្រា ១២**

១. រដ្ឋភាគីទាំងឡាយ ត្រូវផ្តល់ទៅឱ្យគ្នាទៅវិញទៅមក នូវជំនួយដែលទាក់ទងទៅនឹងការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ ឬនីតិវិធីព្រហ្មទណ្ឌ ឬនីតិវិធីនៃការធ្វើបត្យាប័ន ចំពោះបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ដោយរួមបញ្ចូលទាំងការផ្តល់ជាជំនួយដល់ការទទួលភស្តុតាងចាំបាច់សម្រាប់នីតិវិធី ដែលស្ថិតនៅក្នុងការកាន់កាប់របស់ខ្លួនផង ។

២. រដ្ឋភាគីទាំងឡាយ មិនអាចបដិសេធនូវសំណើសុំឱ្យមានការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ដោយលើកហេតុផលអំពីការសម្ងាត់របស់ធនាគារ ឡើយ ។

៣. រដ្ឋដែលធ្វើសំណើ មិនត្រូវបញ្ជូន ឬប្រើប្រាស់ពត៌មាន ឬភស្តុតាង ដែលផ្តល់ឱ្យដោយរដ្ឋដែលទទួលសំណើ សម្រាប់ការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធី ក្រៅអំពីអ្វីដែលបានកំណត់នៅក្នុងសំណើ ដោយគ្មានការយល់ព្រមជាមុន របស់រដ្ឋដែលទទួលសំណើ ឡើយ ។

៤. រដ្ឋភាគីនីមួយៗ អាចធ្វើការពិចារណាអំពីការបង្កើតយន្តការសម្រាប់ការចែករំលែកជាមួយនឹងរដ្ឋភាគីដទៃទៀត នូវពត៌មាន ឬភស្តុតាង ដែលត្រូវការចាំបាច់សម្រាប់ការបង្កើតឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬរដ្ឋបាល តាមមាត្រា៥ ខាងលើ ។

៥ រដ្ឋភាគីទាំងឡាយ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដែលបានកំណត់នៅក្នុងកថាខ័ណ្ឌទី១ និងទី២ ខាងលើ ឱ្យស្របទៅតាមសន្ធិសញ្ញា ឬការព្រមព្រៀងដទៃទៀត ស្តីអំពីការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក ឬអំពីការផ្លាស់ប្តូរពត៌មាន ដែលអាចនឹងមានរវាងរដ្ឋទាំងនោះ ។ ប្រសិនបើពុំមានសន្ធិសញ្ញា ឬការព្រមព្រៀងបែបនេះទេ រដ្ឋភាគីទាំងឡាយ ត្រូវផ្តល់ជំនួយទៅឱ្យគ្នាទៅវិញទៅមក ទៅតាមច្បាប់ជាតិរបស់ខ្លួន ។

**មាត្រា ១៣**

សម្រាប់គោលបំណងនៃការធ្វើបត្យាប័ន ឬការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក គ្មានបទល្មើសណាមួយក្នុងចំណោមបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ត្រូវបានចាត់ទុកថាជាបទល្មើសសារពើពន្ធឡើយ ។ ហេតុដូច្នេះហើយ រដ្ឋភាគីទាំងឡាយ មិនអាចបដិសេធសំណើសុំបត្យាប័ន ឬសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ដោយសំអាងលើមូលហេតុថា រឿងនោះពាក់ព័ន្ធទៅនឹងបទល្មើសសារពើពន្ធ បានឡើយ ។

**មាត្រា ១៤**

សម្រាប់គោលបំណងនៃការធ្វើបត្យាប័ន ឬការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក គ្មានបទល្មើសណាមួយក្នុងចំណោមបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ត្រូវបានចាត់ទុកថាជាបទល្មើសនយោបាយ ឬជាបទល្មើសដែលមានការពាក់ព័ន្ធទៅនឹងបទល្មើសនយោបាយ ឬជាបទល្មើសដែលកើតឡើងដោយសារហេតុផលនយោបាយឡើយ ។ ហេតុដូច្នេះហើយ សំណើសុំបត្យាប័ន ឬសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ដែលបានធ្វើឡើងដោយផ្អែកលើបទល្មើសនោះ ពុំអាចត្រូវបានបដិសេធ ដោយសំអាងលើមូលហេតុថា រឿងនោះមានការទាក់ទងទៅនឹងបទល្មើសនយោបាយ ឬបទល្មើសដែលមានការពាក់ព័ន្ធទៅនឹងបទល្មើសនយោបាយ ឬបទល្មើសដែលកើតឡើងដោយសារហេតុផលនយោបាយ បានឡើយ ។

**មាត្រា ១៥**

គ្មានបញ្ញត្តិណាមួយនៅក្នុងអនុសញ្ញានេះ ត្រូវបានបកស្រាយថាជាការដាក់បន្ទុកកាតព្វកិច្ចឱ្យធ្វើបត្យាប័ន ឬឱ្យផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកឡើយ ប្រសិនបើរដ្ឋភាគីដែលបានទទួលសំណើ មានហេតុផលសំខាន់ដែលអាចឱ្យជឿបានថា សំណើសុំបត្យាប័នលើបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ឬសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកចំពោះបទល្មើសទាំងនោះ ត្រូវបានធ្វើឡើងក្នុងគោលបំណងធ្វើការចោទប្រកាន់ ឬ ដាក់ទោសទៅលើជននោះ ដោយសារតែពូជសាសន៍ សាសនា សញ្ជាតិ ជាតិពន្ធ ឬគំនិតនយោបាយរបស់ជននោះ ឬ មានហេតុផលសំខាន់ដែលអាចឱ្យជឿបានថា ការយល់ព្រមធ្វើតាមសំណើនោះ នឹងធ្វើឱ្យមានការប៉ះពាល់ដល់ស្ថានភាពរបស់ជននោះ ដោយសារមូលហេតុដូចពោលខាងលើ ។

**មាត្រា ១៦**

១. ជនណាម្នាក់ដែលកំពុងជាប់ឃុំ ឬកំពុងទទួលទោសនៅលើទឹកដីនៃរដ្ឋភាគីមួយ ហើយមានសំណើសុំឱ្យមានវត្តមានរបស់ជននោះនៅលើទឹកដីនៃរដ្ឋភាគីមួយទៀត សម្រាប់គោលបំណងនៃការកំណត់អត្តសញ្ញាណ ការផ្តល់ចម្លើយកសិណសាក្សី ឬ ការផ្តល់ជំនួយនៅក្នុងការទទួលយកភស្តុតាង ដែលមានប្រយោជន៍សម្រាប់ការស៊ើបអង្កេត ឬការចោទប្រកាន់លើបទល្មើសដែលមានចែងនៅក្នុងមាត្រា២. អាចត្រូវបានផ្ទេរ ប្រសិនបើបានបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

(ក) បុគ្គលនោះ បានផ្តល់ការយល់ព្រមរបស់ខ្លួន ដោយសេរី

(ខ) អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋទាំងពីរ បានព្រមព្រៀងគ្នា ទៅតាមល័ក្ខខ័ណ្ឌផ្សេងៗដែលរដ្ឋទាំងពីរនោះអាចនឹងយល់ឃើញថាសមរម្យ ។

២. សម្រាប់គោលបំណងនៃមាត្រានេះ :

(ក) រដ្ឋដែលទទួលការបញ្ជូនជនដែលបានពោលខាងលើ ត្រូវមានសិទ្ធិអំណាច និងកាតព្វកិច្ចរក្សាទុកជននោះនៅក្នុងមន្ទីរឃុំឃាំង លើកលែងតែករណីមានសំណើ ឬការអនុញ្ញាតឱ្យធ្វើផ្សេងពីនេះ ដោយរដ្ឋដែលធ្វើការបញ្ជូនខ្លួនជននោះ ។

(ខ) រដ្ឋដែលទទួលការបញ្ជូន ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដោយគ្មានការយឺតយ៉ាវ ក្នុងការបញ្ជូនជននោះឱ្យត្រឡប់ទៅស្ថិតក្នុងការឃុំឃាំងរបស់រដ្ឋដែលធ្វើការបញ្ជូនវិញ ទៅតាមអ្វីដែលបានព្រមព្រៀងគ្នាជាមុន ឬទៅតាមការព្រមព្រៀងផ្សេងទៀតរវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទាំងពីរ ។

(គ) រដ្ឋដែលបានទទួលការបញ្ជូន មិនត្រូវទាមទារឱ្យរដ្ឋដែលបានធ្វើការបញ្ជូន ផ្តួចផ្តើមនីតិវិធីនៃបត្យាប័ន ដើម្បីសុំឱ្យខ្លួនបញ្ជូនជននោះត្រឡប់ទៅវិញ ឡើយ ។

(ឃ) ជនដែលត្រូវបានបញ្ជូន ត្រូវទទួលការកាត់កងទោសដែលខ្លួនកំពុងទទួលរងនៅក្នុងរដ្ឋដែលបានធ្វើការបញ្ជូនដោយរយៈពេលដែលខ្លួនចំណាយនៅក្នុងការឃុំឃាំងរបស់រដ្ឋបានទទួលការបញ្ជូន ។

៣. លើកលែងតែមានការព្រមព្រៀងពីសំណាក់រដ្ឋដែលធ្វើការបញ្ជូនតាមបញ្ញត្តិនៃមាត្រានេះ ជនដែលត្រូវបានបញ្ជូនទោះជាជននោះមានសញ្ជាតិអ្វីក៏ដោយ មិនត្រូវទទួលរងការកាត់ទោស ឬជាប់ឃុំឃាំង ឬស្ថិតនៅក្រោមការរឹតបន្តឹងផ្សេងៗទៀតទៅលើសេរីភាពបុគ្គលរបស់ខ្លួន នៅលើទឹកដីនៃរដ្ឋដែលបានទទួលការបញ្ជូនឡើយ ចំពោះសកម្មភាព ឬការចោទប្រកាន់ដែលកើតឡើងនៅមុនពេលដែលជននោះចាកចេញពីទឹកដីនៃប្រទេសដែលធ្វើការបញ្ជូន ។

**មាត្រា ១៧**

ជនណាក៏ដោយ ដែលត្រូវបានឃុំឃាំង ឬដែលវិធានការផ្សេងទៀតត្រូវបានចាត់លើខ្លួន ឬដែលនីតិវិធីត្រូវបានអនុវត្តលើខ្លួន ដោយអនុលោមទៅតាមអនុសញ្ញានេះ, ត្រូវបានទទួលការធានានូវការប្រព្រឹត្តចំពោះដោយយុត្តិធម៌ ដែលរួមមានការទទួលបាននូវសិទ្ធិ និងការធានាគ្រប់បែបយ៉ាង ទៅតាមច្បាប់របស់រដ្ឋដែលជននោះមានវត្តមាន និងទៅតាមបទបញ្ញត្តិជាធរមាននៃច្បាប់អន្តរជាតិ រួមបញ្ចូលទាំងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សផង ។

**មាត្រា ១៨**

១. រដ្ឋភាគីទាំងឡាយត្រូវធ្វើសហប្រតិបត្តិការ ក្នុងការបង្ការបទល្មើសនានាដែលមានចែងនៅក្នុងមាត្រា២ ដោយត្រូវចាត់វិធានការផ្សេងៗ ដែលក្នុងនោះមានការសម្របសម្រួលបទដ្ឋានគតិយុត្តិជាតិរបស់ខ្លួន ប្រសិនបើចាំបាច់ ដើម្បីបង្ការ និងបង្ក្រាបការត្រៀមរៀបចំនៅលើទឹកដីរបស់ខ្លួន នូវបទល្មើសដែលត្រូវប្រព្រឹត្តនៅក្នុង ឬនៅក្រៅទឹកដីរបស់ខ្លួន, រួមមាន ៖

(ក) វិធានការហាមឃាត់ នៅលើទឹកដីរបស់ខ្លួន នូវសកម្មភាពខុសច្បាប់របស់បុគ្គល ឬអង្គការផ្សេងៗ ដែលលើកទឹកចិត្ត ញុះញង់ រៀបចំ ឬជំរុញ ដោយចេតនា ឱ្យមានការប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងមាត្រា២

(ខ) វិធានការដែលតម្រូវឱ្យស្ថាប័នហិរញ្ញវត្ថុ ឬវិជ្ជាជីវៈផ្សេងទៀតដែលជាប់ទាក់ទងទៅនឹងប្រតិបត្តិការហិរញ្ញវត្ថុ ប្រើប្រាស់នូវវិធានការដែលមានប្រសិទ្ធិភាពជាងគេបំផុត និងដែលអាចធ្វើបាន ក្នុងការកំណត់អត្តសញ្ញាណរបស់អតិថិជនប្រចាំ និងអតិថិជនម្តងមួយគ្រារបស់ខ្លួន ក៏ដូចជាអតិថិជនដែលជាម្ចាស់ផលប្រយោជន៍លើគណនីដែលត្រូវបានបើក. និងតម្រូវឱ្យយកចិត្តទុកដាក់ជាពិសេស ទៅលើប្រតិបត្តិការមិនធម្មតា ឬ គួរឱ្យសង្ស័យ ហើយត្រូវរាយការណ៍អំពីប្រតិបត្តិការទាំងឡាយណា ដែលត្រូវបានសង្ស័យថាកើតចេញមកពីសកម្មភាពព្រហ្មទណ្ឌ។ ក្នុងគោលបំណងនេះ រដ្ឋភាគីទាំងឡាយ ត្រូវគិតគូរអំពីវិធានការដូចខាងក្រោម :

(១) ត្រូវអនុម័តបទបញ្ញាហាមឃាត់ការបើកគណនី ដែលម្ចាស់គណនីនោះ ឬអ្នកទទួលផលប្រយោជន៍ពីគណនីនោះ ពុំត្រូវបានកំណត់អត្តសញ្ញាណ ឬពុំអាចកំណត់អត្តសញ្ញាណបាន, ព្រមទាំងវិធានការនានាដើម្បីធានាថា ស្ថាប័នទាំងនោះធ្វើការផ្ទៀងផ្ទាត់លើអត្តសញ្ញាណរបស់ម្ចាស់ពិតប្រាកដ នៃប្រតិបត្តិការទាំងនោះ

(២) ចំពោះការកំណត់អត្តសញ្ញាណរបស់នីតិបុគ្គលវិញ ត្រូវតម្រូវឱ្យស្ថាប័នហិរញ្ញវត្ថុ ចាត់វិធានការនៅពេលណាចាំបាច់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ទៅលើអត្ថិភាពតាមផ្លូវច្បាប់ និងរចនាសម្ព័ន្ធរបស់អតិថិជនជានីតិបុគ្គល ដោយទទួលយកពីការិយាល័យចុះបញ្ជីសាធារណៈ ឬ ពីអតិថិជននោះ ឬ ពីការិយាល័យចុះបញ្ជីសាធារណៈផង ពីអតិថិជននោះផង នូវភស្តុតាងនៃការបង្កើតនីតិបុគ្គលនោះ រួមមានពត៌មានដែលទាក់ទងទៅនឹងឈ្មោះ ទម្រង់តាមផ្លូវច្បាប់ អាស័យដ្ឋាន អ្នកគ្រប់គ្រង របស់អតិថិជនជានីតិបុគ្គលនោះ ព្រមទាំងបទបញ្ញត្តិដែលគ្រប់គ្រងលើអំណាចដឹកនាំនីតិបុគ្គលនោះផង ។

(៣) ត្រូវបង្កើតបទបញ្ញត្តិដែលដាក់បន្ទុកទៅលើស្ថាប័នហិរញ្ញវត្ថុ នូវកាតព្វកិច្ចធ្វើការរាយការណ៍ជាបន្ទាន់ ជូនអាជ្ញាធរមានសមត្ថកិច្ច នូវប្រតិបត្តិការទាំងឡាយណាដែលមានលក្ខណៈស្មុគស្មាញ មានទំហំធំមិនធម្មតា និងបែបបទមិនធម្មតានៃប្រតិបត្តិការទាំងនោះ ដែលពុំមានគោលបំណងសេដ្ឋកិច្ចជាក់ស្តែង ឬពុំមានគោលបំណងស្របច្បាប់ យ៉ាងច្បាស់ក្រឡែត. ដោយពុំមានការភ័យខ្លាចថាខ្លួននឹងរងនូវការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ដោយសារការបំពានទៅលើការដាក់កម្រិតអំពីការបញ្ចេញពត៌មាន ឡើយ ប្រសិនបើពួកគេធ្វើការរាយការណ៍អំពីក្តីសង្ស័យរបស់ខ្លួន ដោយសុចរិត ។

(៤) ត្រូវតម្រូវឱ្យស្ថាប័នហិរញ្ញវត្ថុ រក្សាទុកនូវរាល់បញ្ជីប្រតិបត្តិការចាំបាច់ ទាំងក្នុងប្រទេស និងអន្តរជាតិ ឱ្យបានយ៉ាងហោចណាស់ប្រាំឆ្នាំ ។

២. រដ្ឋភាគីទាំងឡាយ ត្រូវធ្វើសហប្រតិបត្តិការថែមទៀត នៅក្នុងការបង្ការបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ដោយត្រូវគិតគូរអំពី :

(ក) វិធានការនៃការគ្រប់គ្រង ដែលរួមមានដូចជាការផ្តល់អាជ្ញាប័ណ្ណ ទៅឱ្យរាល់ភ្នាក់ងារបញ្ជូនប្រាក់ ជាដើម

(ខ) វិធានការដែលអាចធ្វើទៅបាន ក្នុងការស៊ើបឱ្យដឹង ឬពិនិត្យតាមដានការនាំយកទៅតាមខ្លួន ដោយឆ្លងកាត់ព្រំដែន នូវសាច់ប្រាក់ និងមូលប័ត្រឥណទេយ្យជូនជូរបាន, ប៉ុន្តែត្រូវធ្វើយ៉ាងណាធានានូវការប្រើប្រាស់ពត៌មានឱ្យបានត្រឹមត្រូវ និងមិនត្រូវធ្វើឱ្យប៉ះពាល់ទៅដល់សេរីភាពក្នុងការធ្វើចរាចរណ៍មូលនិធិឡើយ ទោះតាមវិធីណាក៏ដោយ ។

៣. រដ្ឋភាគីទាំងឡាយ ត្រូវធ្វើសហប្រតិបត្តិការដើម្បីបង្ការបទល្មើសដែលមានចែងនៅក្នុងមាត្រា២ តាមរយៈការផ្លាស់ប្តូរពត៌មានពិតប្រាកដ និងបានផ្ទៀងផ្ទាត់រួច ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន និងតាមរយៈការសម្របសម្រួលនូវវិធានការរដ្ឋបាល និងវិធានការផ្សេងៗទៀត ដែលត្រូវបានចាត់ឡើងទៅតាមភាពសមស្រប ដើម្បីបង្ការបទល្មើសដែលមានចែងនៅក្នុងមាត្រា២, ជាពិសេសតាមរយៈ :

(ក) ការបង្កើត និងរក្សាការពារ នូវបណ្តាញទំនាក់ទំនងរវាងភ្នាក់ងារ និងសេវាមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីសម្រួលដល់ការផ្លាស់ប្តូរពត៌មានទាក់ទងទៅនឹងរាល់ទិដ្ឋភាពនៃបទល្មើសដែលមានចែងនៅក្នុងមាត្រា២ ឱ្យបានរឹងមាំ និងឆាប់រហ័ស ។

(ខ) ការធ្វើសហប្រតិបត្តិការគ្នាទៅវិញទៅមក នៅក្នុងការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងចំណុចដូចខាងក្រោម លើបទល្មើសដែលមានចែងនៅក្នុងមាត្រា២ :

(១) អត្តសញ្ញាណ ទីសំចត និងសកម្មភាព របស់បុគ្គលដែលត្រូវបានសង្ស័យដោយសមហេតុផលថាជនទាំងនោះ ចូលពាក់ព័ន្ធទៅក្នុងបទល្មើសទាំងនោះ

(២) ចរាចរណ៍នៃមូលនិធិដែលទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសទាំងនោះ ។

៤. រដ្ឋភាគីទាំងឡាយ អាចធ្វើការផ្លាស់ប្តូរពត៌មាន តាមរយៈអង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ (Interpol) បាន ។

**មាត្រា ១៩**

រដ្ឋភាគីណាដែលជនល្មើសជាប់ចោទ ត្រូវបានចោទប្រកាន់នៅទីនោះ ត្រូវបញ្ជូនលទ្ធផលចុងក្រោយនៃនីតិវិធី តាមច្បាប់ជាតិ ឬនីតិវិធីដែលត្រូវបានអនុវត្តនៅក្នុងប្រទេសរបស់ខ្លួន ទៅឱ្យអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលត្រូវបញ្ជូនពត៌មាននេះបន្តទៀត ទៅឱ្យរដ្ឋភាគីដទៃទៀត ។

**មាត្រា ២០**

រដ្ឋភាគីទាំងអស់ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញានេះ ឱ្យស្របទៅតាមគោលការណ៍នៃអធិបតេយ្យភាព សមភាព និងបូរណភាពទឹកដីរបស់រដ្ឋ និងគោលការណ៍នៃការមិនចូលអន្តរាគមន៍ទៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ ។

**មាត្រា ២១**

គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ ត្រូវប៉ះពាល់ទៅដល់សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវផ្សេងៗទៀត របស់រដ្ឋ និងបុគ្គលឯកជន តាមច្បាប់អន្តរជាតិ ជាពិសេសតាមគោលបំណងរបស់ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាពាក់ព័ន្ធដទៃទៀត ឡើយ ។

**មាត្រា ២២**

គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ ផ្តល់សិទ្ធិអំណាចទៅដល់រដ្ឋភាគីណាមួយ ឱ្យអនុវត្តនៅលើទឹកដីនៃរដ្ឋភាគីមួយទៀត នូវយុត្តាធិការ ឬមុខងារ ដែលត្រូវបានបម្រុងទុកផ្តាច់មុខ សម្រាប់តែអាជ្ញាធរនៃរដ្ឋភាគីមួយទៀតនោះ តាមច្បាប់ជាតិរបស់រដ្ឋនោះ ឡើយ ។

**មាត្រា ២៣**

១. ឧបសម្ព័ន្ធ អាចត្រូវបានធ្វើវិសោធនកម្ម ដោយការបន្ថែមនូវសន្ធិសញ្ញាពាក់ព័ន្ធផ្សេងៗ ដែល :

(ក) មានលក្ខណៈបើកចំហរ ឱ្យមានការចូលរួមពីសំណាក់រដ្ឋទាំងអស់

(ខ) បានចូលជាធរមានហើយ

(គ) ត្រូវបានផ្តល់សច្ចាប័ន ទទួលស្គាល់ ទទួលយល់ព្រម ឬចូលជាសមាជិក ដោយរដ្ឋភាគីនៃអនុសញ្ញានេះ យ៉ាងហោចណាស់ចំនួន ២២ ។

២. បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន រដ្ឋភាគីណាក៏ដោយ អាចស្នើសុំឱ្យធ្វើវិសោធនកម្មដូចចែងខាងលើនេះបាន ។ សេចក្តីស្នើសុំធ្វើវិសោធនកម្ម ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជូនទៅកន្លែងតម្កល់ ។ កន្លែងតម្កល់ត្រូវជូនដំណឹងអំពីសេចក្តីស្នើដែលបំពេញតាមល័ក្ខខ័ណ្ឌនៃកថាខ័ណ្ឌទី១ ទៅរដ្ឋភាគីទាំងអស់ ហើយស្នើសុំយោបល់របស់រដ្ឋទាំងនោះ ថាតើសំណើសុំធ្វើវិសោធនកម្ម គួរតែអនុម័តយល់ព្រមដែរឬទេ ។

៣. សំណើសុំធ្វើវិសោធនកម្ម ត្រូវចាត់ទុកថាបានអនុម័តយល់ព្រម លើកលែងតែករណីដែលមានរដ្ឋចំនួនមួយភាគបីធ្វើការជំទាស់ទៅនឹងសំណើនោះ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ មិនឱ្យហួសពី ១៨០ ថ្ងៃ បន្ទាប់ពីការផ្សព្វផ្សាយអំពីសំណើនោះ ។

៤. វិសោធនកម្មទៅលើឧបសម្ព័ន្ធ ដែលត្រូវបានអនុម័តយល់ព្រម ត្រូវចូលជាធរមាន ៣០ ថ្ងៃ បន្ទាប់ពីការតម្កល់លិខិតុបករណ៍ទី ២២ នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការយល់ព្រមទទួលវិសោធនីកម្មនោះ ចំពោះរដ្ឋភាគីទាំងឡាយដែលបានតម្កល់លិខិតុបករណ៍នោះ ។ ចំពោះរដ្ឋភាគីណា ដែលផ្តល់សច្ចាប័ន ទទួលស្គាល់ ឬទទួលយល់ព្រមលើវិសោធនកម្ម

ក្រោយពីការតម្កល់លិខិតូបករណ៍ទី ២២ វិសោធនកម្មនោះត្រូវចូលជាធរមាន នៅថ្ងៃទី៣០ បន្ទាប់ពីការតម្កល់លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការទទួលយល់ព្រម ដោយរដ្ឋនោះ ។

### មាត្រា ២៤

១. ទំនាស់ដែលកើតមានរវាងរដ្ឋភាគីពីរ ឬច្រើន ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ហើយដែលមិនអាចផ្សះផ្សារគ្នា តាមរយៈការចរចារ នៅក្នុងពេលមួយដ៏សមស្របបានទេ ត្រូវដាក់បញ្ជូនទៅមជ្ឈត្តករ តាមសំណើរបស់រដ្ឋមួយ ក្នុងចំណោមរដ្ឋទាំងពីរ ។ ប្រសិនបើក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើសុំដោះស្រាយតាមរយៈមជ្ឈត្តកម្ម ភាគីពុំអាចព្រមព្រៀងគ្នាទៅលើការរៀបចំប្រព័ន្ធមជ្ឈត្តកម្មទេ ភាគីណាមួយក្នុងចំណោមភាគីទាំងនោះ អាចបញ្ជូនទំនាស់ខាងលើ ទៅតុលាការអន្តរជាតិ (ICJ) តាមពាក្យសុំ ដោយអនុលោមទៅតាមលក្ខន្តិកៈនៃតុលាការអន្តរជាតិ បាន ។

២. នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ទទួលស្គាល់ ទទួលយល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋនីមួយៗ អាចធ្វើការប្រកាសថា ខ្លួនមិនចាត់ទុកខ្លួនឯងជាត្រូវបានចងដោយកថាខ័ណ្ឌទី១ ខាងលើនេះទេ ។ រដ្ឋភាគីដទៃទៀត មិនត្រូវចងដោយកថាខ័ណ្ឌទី១ ឡើយ ចំពោះមុខរដ្ឋភាគីណាមួយដែលបានប្រកាសខបំរុងខាងលើនេះ ។

៣. រដ្ឋណាមួយដែលបានប្រកាសខបំរុងតាមកថាខ័ណ្ឌទី២ ខាងលើនេះ អាចដកការប្រកាសនោះវិញ នៅពេលណាក៏បាន ដោយជូនដំណឹងទៅឱ្យអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

### មាត្រា ២៥

១. អនុសញ្ញានេះ ត្រូវបើកឱ្យចុះហត្ថលេខាដោយរដ្ឋទាំងអស់ ចាប់ពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ នៅទីស្នាក់ការអង្គការសហប្រជាជាតិ នាទីក្រុងញូយ៉ក ។

២. អនុសញ្ញានេះ អាចត្រូវបានផ្តល់សច្ចាប័ន ទទួលស្គាល់ ឬទទួលយល់ព្រម ។ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការទទួលយល់ព្រម ត្រូវដាក់តម្កល់នៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

៣. រដ្ឋណាក៏ដោយ អាចចូលជាសមាជិកនៃអនុសញ្ញានេះ បាន។ លិខិតូបករណ៍នៃការចូលជាសមាជិក ត្រូវដាក់តម្កល់នៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

### មាត្រា ២៦

១. អនុសញ្ញានេះ ត្រូវចូលជាធរមាន នៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតូបករណ៍ទី២២ នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការទទួលយល់ព្រម ឬការចូលជាសមាជិក នៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ទទួលស្គាល់ ទទួលយល់ព្រម ឬចូលជាសមាជិកនៃអនុសញ្ញានេះ នៅក្រោយការតម្កល់លិខិតុបករណ៍ទី២២ នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការទទួលយល់ព្រម ឬការចូលជាសមាជិក, អនុសញ្ញានេះត្រូវចូលជាសមាជិក នៅថ្ងៃទី៣០ បន្ទាប់ពីការតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលស្គាល់ ការទទួលយល់ព្រម ឬការ ចូលជាសមាជិក ដោយរដ្ឋនោះ ។

**មាត្រា ២៧**

១. រដ្ឋភាគីណាក៏ដោយ អាចប្រកាសបដិសេធអនុសញ្ញានេះបាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

២. ការប្រកាសបដិសេធ ត្រូវមានអានុភាព មួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹង ដោយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

**មាត្រា ២៨**

ច្បាប់ដើមនៃអនុសញ្ញានេះ ដែលអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា ត្រូវតម្កល់នៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលត្រូវផ្ញើច្បាប់ចម្លងដែលមានសេចក្តីបញ្ជាក់នៃអនុសញ្ញានេះជូនទៅរដ្ឋទាំងអស់ ។

អាស្រ័យហេតុនេះហើយ អ្នកចុះហត្ថលេខាខាងក្រោម ដែលបានទទួលការអនុញ្ញាតយ៉ាងត្រឹមត្រូវ ពីសំណាក់រដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញានេះ ដែលត្រូវបានបើកឱ្យចុះហត្ថលេខានៅទីស្នាក់ការអង្គការសហប្រជាជាតិ នាទីក្រុងញូយ៉ក នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០ ។

**ឧបសម្ព័ន្ធ :**

១. អនុសញ្ញាស្តីពីការលុបបំបាត់ការដណ្តើមយកដោយខុសច្បាប់ នូវអាកាសយាន ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៧០ នៅទីក្រុងឡាអេ ។

២. អនុសញ្ញាស្តីពីការលុបបំបាត់សកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនៃអាកាសចរណ៍ស៊ីវិល ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ១៩៧១ នៅទីក្រុងម៉ុងរ៉េអាល់ ។

៣. អនុសញ្ញាស្តីពីការបង្ការ និងការដាក់ទោសលើឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារជាអន្តរជាតិ រួមទាំងភ្នាក់ងារការទូតផង. ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៧៥ ។

៤. អនុសញ្ញាអន្តរជាតិ ប្រឆាំងទៅនឹងការចាប់ជាចំណាប់ខ្មាំង. ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ១៩៧៩ ។

៥. អនុសញ្ញាស្តីពីការការពាររាងកាយ ពីសម្ភារៈនុយក្លេអ៊ែ. ដែលត្រូវបានអនុម័តនៅទីក្រុងវៀន នៅថ្ងៃទី៣ ខែមីនា ឆ្នាំ ១៩៨០ ។

៦. ពិធីសារស្តីពីការលុបបំបាត់សកម្មភាពខុសច្បាប់នៃអំពើហិង្សា នៅអាកាសយានដ្ឋានដែលបំរើឱ្យអាកាសចរណ៍ស៊ីវិលអន្តរជាតិ. ដែលជាពិធីសារបន្ថែមទៅលើអនុសញ្ញាស្តីពីការលុបបំបាត់សកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនៃអាកាសចរណ៍ស៊ីវិល. ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៨៨ នៅទីក្រុងម៉ុងរ៉េអាល់ ។

៧. អនុសញ្ញាស្តីពីការលុបបំបាត់សកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនៃនាវាចរណ៍តាមផ្លូវសមុទ្រ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៨៨ នៅទីក្រុងរ៉ូម ។

៨. ពិធីសារស្តីពីការលុបបំបាត់សកម្មភាពខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពនៃវេទិកាអចិន្ត្រៃយ៍ ដែលស្ថិតនៅលើខនជីលានថល សេល (Continental Shelf). ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៨៨ ។

៩. អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការទំលាក់គ្រាប់បែកភេរវកម្ម. ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ១៩៩៧ ។